| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(207.950)** | **(242.300)** | **(844.277)** | **(992.219)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់សងប្រាក់កម្ចីធនាគារ | | (90.320) | (83.029) | (366.700) | (340.002) |
| ភាគលាភបានបង់ | | (300.000) | (400.000) | (1.218.000) | (1.638.000) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(390.320)** | **(483.029)** | **(1.584.700)** | **(1.978.002)** |
| **កំណើន (ការថយចុះ) សុទ្ធក្នុងសាច់ប្រាក់** | | **108.186** | **283.802** | 439.967 | 1.162.209 |
| សាច់ប្រាក់ | | 773.189 | 489.388 | 3.139.148 | 2.004.043 |
| ភាពខុសគ្នានៃការបកប្រែរូបិយប័ណ្ណ | 2.1 | - | - | (3.579.115) | (15.505) |
| **សាច់ប្រាក់នៅចុងឆ្នាំ** | | **881.376** | **773.189** | **0** | **3.150.746** |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

## ១. ព័ត៌មានទូទៅ

Cute Candle Company Limited ("ក្រុមហ៊ុន") មានការិយាល័យចុះបញ្ជី និងទីកន្លែងប្រកបអាជីវកម្មគោលស្ថិតនៅ ផ្ទះលេខ ៦៤ ផ្លូវ ១០៨ សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺ ផលិត និងលក់ទៀន។

## ២. មូលដ្ឋានក្នុងការរៀបចំ និងគោលនយោបាយគណនេយ្យសំខាន់ៗ

របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមនៃកម្ពុជា ("CIFRS for SMEs") ដែលចេញផ្សាយដោយនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម ("IFRS for SMEs") ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។ គោលនយោបាយគណនេយ្យគោរពតាមការតម្រូវនានារបស់ CIFRS for SMEs និង IFRS for SMEs។ គោលនយោបាយគណនេយ្យ និងជម្រើសនៃគោលនយោបាយសំខាន់ៗរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ដូចខាងក្រោម។

កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជា CIFRS for SMEs និង IFRS for SMEs គឺនៅថ្ងៃទី១ ខែមករាឆ្នាំ២០១៩។ ទាំងនេះគឺជារបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅដែលត្រូវបានរៀបចំឡើងដោយក្រុមហ៊ុននេះ ដូច្នេះគ្មានការកែប្រែគោលនយោបាយឬការវាស់វែង ពីរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅពីមុនណាមួយឡើយ។

### ២.១ រូបិយប័ណ្ណ

របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានបង្ហាញជាដុល្លារអាមេរិក និង ប្រាក់រៀល។ រូបិយប័ណ្ណដុល្លារអាមេរិក គឺជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន និងប្រាក់រៀលជារូបិយប័ណ្ណសម្រាប់ការបង្ហាញបន្ថែម។ ចំណូលពីការលក់ និងចំណាយរបស់ក្រុមហ៊ុនត្រូវបានកំណត់ និងទូទាត់ជាដុល្លារអាមេរិកជាចម្បង។ ការបកប្រែចំនួនទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ ទ្រព្យសកម្មនិងបំណុលត្រូវបានបកប្រែដោយប្រើអត្រាចុងគ្រាសម្រាប់ឆ្នាំនីមួយៗ ចំណាយ ប្រាក់ទទួលនិងប្រាក់ទូទាត់ត្រូវបានបកប្រែដោយប្រើអត្រាមធ្យមសម្រាប់ឆ្នាំនីមួយៗ មូលធនភាគហ៊ុនត្រូវបានបកប្រែដោយប្រើអត្រាប្រវត្តិសាស្ត្រ។

ភាពខុសគ្នាដែលកើតឡើងលើការបកប្រែរបាយការណ៍ចំណូលពេញលេញ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងចំណូលលម្អិតផ្សេងៗ ហើយត្រូវបានកត់ត្រាក្នុងមូលធននៅក្នុងប្រាក់បម្រុងនៃការបកប្រែមួយ។ ភាពខុសគ្នាដែលកើតចេញពីការបកប្រែរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានបង្ហាញជាធាតុសម្របសម្រួលមួយនៅផ្នែកខាងក្រោមនៃរបាយការណ៍លំហូរសាច់ប្រាក់មុននឹងគណនាសមតុល្យសាច់ប្រាក់ចុងគ្រា។ ដោយហេតុថាទាំងនេះជារបាយការណ៍ហិរញ្ញវត្ថុទីមួយដែលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម យើងខ្ញុំបានជ្រើសរើសចាប់ផ្តើមជាមួយនឹងសមតុល្យសូន្យនៅលើប្រាក់បម្រុងការបកប្រែគិតត្រឹមថ្ងៃទី១ខែមករាឆ្នាំ២០១៩ យើងខ្ញុំក៏បានជ្រើសរើសបកប្រែមូលធនភាគហ៊ុនដោយប្រើប្រាស់អត្រាប្តូរប្រាក់ដើមគ្រានៃគ្រាដំបូង។

អត្រាប្តូរប្រាក់ផ្អែកលើការប្រកាសដោយធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

| **កាលបរិច្ឆេទ** | **៛/$** |
|---|---|
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | 4015 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | 4075 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | 4045 |
| អត្រាមធ្យម សម្រាប់ឆ្នាំ ២០១៩ | 4095 |
| អត្រាមធ្យម សម្រាប់ឆ្នាំ ២០២០ | 4060 |

## ៣. ចំណូលពីការលក់

ចំណូលពីការលក់ទំនិញ ត្រូវបានទទួលស្គាល់នៅពេលដែលទំនិញត្រូវបានប្រគល់ដោយក្រុមហ៊ុន ហើយភាពជាម្ចាស់កម្មសិទ្ធិនៃទំនិញត្រូវបាន ផ្ទេរនៅពេលដែលអតិថិជនចុះហត្ថលេខាទទួលនៅលើលិខិតប្រគល់ទំនិញ។ ចំណូលពីការលក់ត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬនឹងត្រូវទទួល ជាតួលេខសុទ្ធក្រោយគិតការបញ្ចុះតម្លៃ និងអាករលើតម្លៃបន្ថែមដែលប្រមូលជំនួសឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

| | | | កំណត់សម្គាល់ ២.១ | |
|---|---|---|---|---|
| | 2020 | 2019 | 2020 | 2019 |
| | $ | $ | ៛'000 | ៛'000 |
| ការលក់ទំនិញ | 7.008.730 | 6.037.830 | 28.350.313 | 24.604.157 |

## ៤. ចំណូលថ្លៃជួល

ចំណូលថ្លៃជួលក្នុងឆ្នាំ២០២០ ចំនួន $៨៨.៨៥០ (៛៣៥៩.៣៩៨.២៥០) និងឆ្នាំ២០១៩ ចំនួន $២៥.០០០ (៛១០១.៨៧៥.០០០) គឺរកបានពីភតិសន្យាប្រតិបត្តិការនៃឃ្លាំងមួយ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុននិងត្រូវបានទទួលស្គាល់ជាទ្រព្យវិនិយោគ។ ក្នុងឆ្នាំ២០២០ ទ្រព្យនេះត្រូវបានជួលទៅឱ្យអ្នកជួលថ្មីសម្រាប់រយៈពេលដែលបញ្ចប់ក្នុងខែកក្កដា ឆ្នាំ២០២២ ដោយពុំមានប្រាក់កក់ជានាឡើយ។ ការទូទាត់ភតិសន្យាមិនអាចលុបចោលបានដល់កាលដូចខាងក្រោម៖

| **ការទូទាត់ថ្លៃជួល ដែលនឹងត្រូវបានទទួល** | | | កំណត់សម្គាល់ ២.១ | |
|---|---|---|---|---|
| | 2020 | 2019 | 2020 | 2019 |
| | $ | $ | ៛'000 | ៛'000 |
| ក្នុងរយៈពេលមួយឆ្នាំ | 88.850 | 25.000 | 359.398 | 101.875 |
| យូរជាងមួយឆ្នាំ ប៉ុន្តែក្នុងរយៈពេលប្រាំឆ្នាំ | 44.400 | - | 179.598 | - |
| យូរជាងប្រាំឆ្នាំ | - | - | - | - |
| **ថ្លៃជួលត្រូវទទួលនាពេលអនាគតសរុប** | **133.250** | **25.000** | **538.996** | **101.875** |

## ៥. ទ្រព្យវិនិយោគ

ទ្រព្យវិនិយោគត្រូវបានទទួលស្គាល់ដំបូងបង្អស់តាមថ្លៃដើម ហើយត្រូវបានវាស់វែងឡើងវិញជាតម្លៃសមស្របនៅចុងឆ្នាំនីមួយៗ។ ទ្រព្យវិនិយោគមិនត្រូវបានរំលស់ឡើយ។ ទ្រព្យវិនិយោគរបស់ក្រុមហ៊ុនរួមមាន ឃ្លាំងមួយ និងដីដែលឃ្លាំងនេះស្ថិតនៅពីលើ។ ទ្រព្យវិនិយោគត្រូវបានប្រើប្រាស់ដើម្បីបង្កើតចំណូលថ្លៃជួលដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ទី ៤ ខាងលើ។

ទ្រព្យនេះត្រូវបានវាយតម្លៃដោយអ្នកវាយតម្លៃឯករាជ្យមួយរូប ដែលមានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធីសាស្ត្រការវាយតម្លៃ គឺជាវិធីសាស្ត្រប្រៀបធៀប ដោយប្រើប្រាស់តម្លៃលក់ថ្មីៗនៃទ្រព្យអាចប្រៀបធៀបបាន។ ភាពត្រឹមត្រូវនៃវិធីសាស្ត្រការវាយតម្លៃនេះ ត្រូវបានកម្រិតដោយការលក់មិនញឹកញយនៃទ្រព្យប្រហាក់ប្រហែលក្នុងតំបន់។

| | ដី និង អគារ | កំណត់សម្គាល់ ២.១<br>ដី និង អគារ |
|---|---|---|
| | $ | ៛'000 |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | 283.000 | 1.144.735 |
| បន្ថែម | - | - |
| ចំណេញ / (ខាត) តម្លៃសមស្រប | (10.000) | (40.600) |
| ចំណេញ / (ខាត) ការបកប្រែរូបិយប័ណ្ណ | - | 150 |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **273.000** | **1.104.285** |

## ៦. ចំណាយថ្លៃជួល. ថ្លៃជួលត្រូវសង

ចំណាយថ្លៃជួលគឺជាថ្លៃដើមនៃការជួលដែលបូករួមលំហលក់រាយនិងការិយាល័យលក់។ កិច្ចព្រមព្រៀងភតិសន្យានេះមានរយៈពេលបួនឆ្នាំ ដោយនៅសល់ ១៨ ខែទៀត។ ការទូទាត់ថ្លៃជួលថេរត្រូវបានធ្វើឡើងជារៀងរាល់ខែ។ កិច្ចព្រមព្រៀងជួលនេះត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ ព្រោះលក្ខខណ្ឌនៃកិច្ចព្រមព្រៀងជួល មិនបានផ្ទេរហានិភ័យ និងតម្លៃតបស្នងនៃភាពជាម្ចាស់កម្មសិទ្ធិសឹងតែទាំងអស់នៃទ្រព្យសកម្មភតិសន្យានេះទៅឱ្យ។ នៅចុងឆ្នាំ ក្រុមហ៊ុនមានការទូទាត់មិនអាចលុបចោលបានមិនទាន់សង ដែលបានសន្យាក្រោមកិច្ចព្រមព្រៀងជួលដូចខាងក្រោម៖

| **ការទូទាត់ថ្លៃជួល** | | | **កំណត់សម្គាល់ ២.១** | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| ការទូទាត់ភតិសន្យាអប្បបរមាក្រោម | **$** | **$** | **៛'000** | **៛'000** |
| ភតិសន្យាប្រតិបត្តិការ ដែលត្រូវបាន ទទួលស្គាល់ | | | | |
| **ជាចំណាយមួយក្នុងឆ្នាំ** | **240.000** | **240.000** | **974.400** | **982.800** |
| ក្នុងរយៈពេលមួយឆ្នាំ | 240.000 | 240.000 | 970.800 | 978.000 |
| យូរជាងមួយឆ្នាំ ប៉ុន្តែក្នុងរយៈពេលប្រាំឆ្នាំ | 120.000 | 360.000 | 485.400 | 1.467.000 |
| យូរជាងប្រាំឆ្នាំ | - | - | - | - |
| **ថ្លៃជួលត្រូវបង់សរុប** | **360.000** | **600.000** | **1.456.200** | **2.445.000** |

## ៧. ចំណាយពន្ធលើប្រាក់ចំណូល និងពន្ធបច្ចុប្បន្ន

ចំណាយពន្ធលើប្រាក់ចំណូលរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យារ (សូមមើលកំណត់សម្គាល់ទី ១៣ អំពីពន្ធពន្យារ)។ ចំណាយពន្ធលើប្រាក់ចំណូល ត្រូវបានទទួលស្គាល់នៅក្នុងចំណេញឬខាត។ ពន្ធបច្ចុប្បន្ន គឺជាពន្ធបានបង់និងត្រូវបង់ទៅតាមចំណូលជាប់ពន្ធសម្រាប់ឆ្នាំ ដោយប្រើប្រាស់អត្រាពន្ធបានអនុម័ត ឬបានអនុម័តជាក់ស្តែងនៅចុងឆ្នាំ និងការសម្របសម្រួលណាក៏ដោយទៅលើពន្ធបច្ចុប្បន្ននៃឆ្នាំមុនៗ។ ពន្ធគឺត្រូវបង់ជាប្រាក់រៀល ផលចំណេញនិងខាតការប្តូររូបិយប័ណ្ណបរទេសត្រូវបានរួមបញ្ចូលក្នុងចំណូលហិរញ្ញវត្ថុនិងថ្លៃដើមហិរញ្ញវត្ថុ។

| | | | **កំណត់សម្គាល់ ២.១** | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| | **$** | **$** | **៛'000** | **៛'000** |
| ពន្ធបច្ចុប្បន្នត្រូវបង់ | 103.390 | 153.904 | 418.214 | 627.157 |
| ឥណទានពន្ធកាត់ទុកលើចំណូលថ្លៃជួល និងការប្រាក់ | 8.885 | 2.500 | 35.940 | 10.188 |

| | | | | |
|---|---|---|---|---|
| **ពន្ធបច្ចុប្បន្ន** | **112.275** | **156.404** | **454.154** | **637.345** |
| បម្រែបម្រួលបំណុលពន្ធពន្យាទ្រព្យសកម្ម (កំណត់សម្គាល់ ១៣) | 17.520 | 23.133 | 70.870 | 94.268 |
| (ចំណេញ) / ខាត ការបកប្រែរូបិយប័ណ្ណ | - | - | 1.684 | 3.128 |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **129.796** | **179.537** | **525.024** | **731.612** |

ពន្ធលើប្រាក់ចំណូលត្រូវបានគណនាដោយប្រើអត្រា ២០% នៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។ ចំណាយពន្ធខុសពីប្រាក់ចំណេញមុនគិតពន្ធ គុណនឹងអត្រាពន្ធ ដោយសារតែចំណាយមិនអនុញ្ញាតបានដោយរួមទាំងចំណាយបំណុលអាក្រក់ និងការកម្សាន្ត។

## ៨. សន្និធិ

សន្និធិ ត្រូវបានថ្លែងតាមតម្លៃទាបជាង រវាងថ្លៃដើម និងថ្លៃលក់ដកនឹងថ្លៃដើមដើម្បីបញ្ចប់ និងលក់។ ថ្លៃដើមត្រូវបានគណនាដោយប្រើប្រាស់ វិធីសាស្ត្រ ចូលមុន-ចេញមុន (FIFO)។

នៅចុងឆ្នាំនីមួយៗ សន្និធិត្រូវបានវាយតម្លៃការថយចុះតម្លៃដោយការប្រៀបធៀបតម្លៃយោងនៃជាតុនីមួយៗនៃសន្និធិ (ឬក្រុមនៃជាតុប្រហាក់ប្រហែល) ជាមួយនឹងតម្លៃលក់របស់វា ដកនឹងថ្លៃដើមដើម្បីបញ្ចប់និងលក់។ ប្រសិនបើជាតុមួយនៃសន្និធិ (ឬក្រុមនៃជាតុប្រហាក់ប្រហែល) មានការថយចុះតម្លៃ តម្លៃយោងរបស់វាត្រូវបានបន្ថយទៅជាតម្លៃលក់ដកថ្លៃដើមដើម្បីបញ្ចប់និងលក់ និងការខាតពីការថយចុះតម្លៃមួយត្រូវបានទទួលស្គាល់ភ្លាមៗក្នុងចំណេញឬខាត។ ក្នុងឆ្នាំ២០២០មានការថយចុះតម្លៃសន្និធិចំនួន $១១.០០០ (៛៤៤.៩៩៥.០០០) និងក្នុងឆ្នាំ២០១៩ចំនួន $៨.៣០៦ (៛៣៣.៨៤៦.៩៥០) ការថយចុះតម្លៃសន្និធិត្រូវបានកត់ចូលចំណាយផ្សេងៗ។

| | | | កំណត់សម្គាល់ ២.១ | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| | **$** | **$** | **៛'000** | **៛'000** |
| វត្ថុធាតុដើម | 38.300 | 31.900 | 154.924 | 129.993 |
| ផលិតផលកំពុងផលិត | 28.223 | 22.000 | 114.162 | 89.650 |
| ផលិតផលសម្រេច | 45.540 | 31.000 | 184.209 | 126.325 |
| សន្និធិទំនិញប្រើប្រាស់ | **6.901** | **5.664** | **27.915** | **23.081** |
| | **118.964** | **90.564** | **481.209** | **369.048** |

## ៩. ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការខាតពីការថយចុះតម្លៃបង្គរ។ ចំណាយរំលស់ចាត់ចែងថ្លៃដើមនៃទ្រព្យសកម្ម ដកតម្លៃកាកសំណល់របស់ពួកវាទៅតាមអាយុកាលអាចប្រើប្រាស់ប៉ាន់ស្មានរបស់ពួកវាដោយប្រើប្រាស់វិធីសាស្ត្របន្ទាត់ត្រង់។ ប្រសិនបើមានការកែប្រែក្នុងអាយុកាលអាចប្រើប្រាស់ឬតម្លៃកាកសំណល់ ការរំលស់ត្រូវបានកែតម្រូវដោយអនុវត្តទៅមុខ។

ដី និងអគាររួមមាន អគាររោងចក្រមួយ និងដីដែលអគាររោងចក្រនោះស្ថិតនៅពីលើ។ បរិក្ខាររួមមាន បរិក្ខារផលិតទៀន និងគ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ។ អាយុកាលអាចប្រើប្រាស់ប៉ាន់ស្មានដូចខាងក្រោម៖

អគារ ៥០ ឆ្នាំ

បរិក្ខារ ៥ - ៨ ឆ្នាំ

ដីមិនត្រូវបានរំលស់ឡើយ។ ជាតុដី នៃដីនិងអគារត្រូវបានបង្ហាញដោយប្រើប្រាស់ថ្លៃដើមប្រវត្តិសាស្ត្ររបស់វាចំនួន $១.២៥០.០០០។ ដីនិងអគារដែលមានតម្លៃយោងចំនួន $៣.០១៤.០០០ (៛១២.១៩១.៦៣០.០០០) ត្រូវបាន

ដាក់ជាការធានាសម្រាប់ប្រាក់កម្ចីមួយ ដែលមានកាលកំណត់នៅសល់បីឆ្នាំ (សូមមើលកំណត់សម្គាល់ទី១២)។ ក្នុងអំឡុងពេលប្រាក់កម្ចីនេះ ដីនិងអគារមិនអាចត្រូវបាន លក់ឬផ្ទេរកម្មសិទ្ធិឡើយ។

| | **ដី និង អគារ** | **បរិក្ខារ** | **សរុប** |
|---|---|---|---|
| **ថ្លៃដើម** | **$** | **$** | **$** |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | 3.210.000 | 1.549.800 | 4.759.800 |
| ទិញបន្ថែម | - | 207.950 | 207.950 |
| ការបញ្ចេញចោល | - | - | - |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **3.210.000** | **1.757.750** | **4.967.750** |
| **រំលស់និងការថយចុះតម្លៃបង្គរ** | | | |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | 156.800 | 520.600 | 677.400 |
| ចំណាយរំលស់ | 39.200 | 219.719 | 258.919 |
| ការបញ្ចេញចោល | - | - | - |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **196.000** | **740.319** | **936.319** |
| **តម្លៃយោង** | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **3.014.000** | **1.017.431** | **4.031.431** |

**កំណត់សម្គាល់ ២.១**

| | **ដី និង អគារ** | **បរិក្ខារ** | **សរុប** |
|---|---|---|---|
| **ថ្លៃដើម** | **៛'000** | **៛'000** | **៛'000** |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | 13.080.750 | 6.315.435 | 19.396.185 |
| ការបន្ថែម | - | 851.555 | 851.555 |
| ការបញ្ចេញចោល | - | - | - |
| ចំណេញ/(ខាត) ការបកប្រែរូបិយប័ណ្ណ | (96.300) | (56.892) | (153.192) |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **12.984.450** | **7.110.099** | **20.094.549** |
| **រំលស់និងការថយចុះតម្លៃបង្គរ** | | | |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | 638.960 | 2.121.445 | 2.760.405 |
| ចំណាយរំលស់ | 160.524 | 899.748 | 1.060.272 |
| ការបញ្ចេញចោល | - | - | - |
| ចំណេញ/(ខាត) ការបកប្រែរូបិយប័ណ្ណ | (6.664) | (26.604) | (33.268) |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **792.820** | **2.994.589** | **3.787.409** |
| **តម្លៃយោង** | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **12.191.630** | **4.115.509** | **16.307.139** |

## ១០. គណនីត្រូវសង

គណនីត្រូវសង ជាកាតព្វកិច្ចដែលផ្អែកលើលក្ខខណ្ឌឥណទានធម្មតា ហើយមិនគិតការប្រាក់ឡើយ។ គណនីត្រូវសងផ្សេងៗរួមមាន អាករលើតម្លៃបន្ថែមត្រូវបង់ (អតប) និងចំណាយបង្គរ។ គណនីត្រូវសង និងត្រូវសងផ្សេងៗដែលគណនាតម្លៃជាប្រាក់រៀលឬរូបិយប័ណ្ណណាក៏ដោយក្រៅពីដុល្លារអាមេរិកត្រូវបានបកប្រែ ទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅចុងឆ្នាំ។ ចំណេញឬខាតការប្តូររូបិយប័ណ្ណបរទេសត្រូវបានរួមបញ្ចូលក្នុងចំណូលហិរញ្ញវត្ថុនិងថ្លៃដើមហិរញ្ញវត្ថុ ដោយឡែកៗ។ គណនីត្រូវសងនិងត្រូវសងផ្សេងៗនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ រួមមាន $៥០.០៥០ (៛២០២.៤៥២.២៥០) ដែលត្រូវបានគណនាតម្លៃ ជាប្រាក់រៀល; $៤៣.១៩២ (៛១៧៦.០០៧.៤០០) នៅថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៩។

| | 2020 | 2019 | កំណត់សម្គាល់ ២.១<br>2020 | 2019 |
|---|---|---|---|---|
| | $ | $ | ៛'000 | ៛'000 |
| គណនីត្រូវសង | 39.655 | 30.188 | 160.403 | 123.016 |
| អាករលើតម្លៃបន្ថែមត្រូវបង់ | 40.884 | 35.221 | 165.377 | 143.524 |
| ចំណាយបង្គរ | 11.666 | 10.471 | 47.190 | 42.668 |
| | **92.205** | **75.879** | **372.970** | **309.208** |

## ១១. កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីរួមមាន ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការដទៃទៀតដែលត្រូវសងក្នុងរយៈពេល ១២ ខែនៃចុងឆ្នាំ ទៅតាមសេវាកម្ម ដែលបានផ្តល់សម្រាប់ឆ្នាំ។ អត្ថប្រយោជន៍អតីតភាពការងារគឺត្រូវបង់ក្រោមផែនការកំណត់របស់រដ្ឋាភិបាល ហើយរួមមានអត្ថប្រយោជន៍រយៈពេលវែង ដែលត្រូវបានផ្តល់ជូនសម្រាប់សេវាកម្មក្នុងរយៈពេលមុនៗ។ អត្ថប្រយោជន៍អតីតភាពការងាររយៈពេលវែង ត្រូវបានបង្ហាញនៅតម្លៃបច្ចុប្បន្ននៃឆ្នាំនៃការទូទាត់អនាគត ដោយប្រើប្រាស់អត្រាអប្បហារ ៨.៥% (២០១៩: ៨.៥%) ដែលថ្នាក់គ្រប់គ្រងប៉ាន់ស្មានជាអត្រាខ្ចីប្រាក់បច្ចុប្បន្នរបស់ក្រុមហ៊ុន។ ឥទ្ធិពលសុទ្ធនៃការលាតអប្បហារ ក្នុងអំឡុងរយៈពេលត្រូវបានរួមបញ្ចូលក្នុងចំណាយអត្ថប្រយោជន៍និយោជិតសម្រាប់រយៈពេលនោះ។ បំណុលអត្ថប្រយោជន៍ អតីតភាពការងារមិនត្រូវបានផ្តល់ថវិកា។

| | 2020 | 2019 | កំណត់សម្គាល់ ២.១<br>2020 | 2019 |
|---|---|---|---|---|
| | $ | $ | ៛'000 | ៛'000 |
| **អត្ថប្រយោជន៍និយោជិតបច្ចុប្បន្នត្រូវបង់** | | | | |
| អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី | 37.786 | 16.750 | 152.844 | 68.256 |
| ចំណែកបច្ចុប្បន្ននៃអត្ថប្រយោជន៍អតីតភាពការងាររយៈពេលវែង | 16.442 | 18.090 | 66.508 | 73.717 |
| | **54.228** | **34.840** | **219.352** | **141.973** |
| **អត្ថប្រយោជន៍និយោជិតមិនមែនបច្ចុប្បន្នត្រូវបង់** | | | | |
| អត្ថប្រយោជន៍អតីតភាពការងាររយៈពេលវែងត្រូវបង់ | 43.286 | 57.449 | 175.092 | 234.105 |
| **អត្ថប្រយោជន៍និយោជិតសរុបត្រូវបង់** | **97.514** | **92.289** | **394.444** | **376.078** |

## ១២. ប្រាក់កម្ចីពីធនាគារ

ចំណាយការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ហើយត្រូវបានបញ្ចូលទៅក្នុងថ្លៃដើមហិរញ្ញវត្ថុ។ ប្រាក់កម្ចីនេះត្រូវបានធានាដោយសិទ្ធិឃាត់ទុកអណ្តែតមួយទៅលើ អគាររោងចក្រមួយនិងដីកាន់កាប់ដោយក្រុមហ៊ុននេះ (សូមមើលកំណត់សម្គាល់ទី៩)។

ការប្រាក់គឺត្រូវបង់ទៅលើសមតុល្យមិនទាន់សងនៃប្រាក់កម្ចីធនាគាររយៈពេលប្រាំឆ្នាំ ដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាពប្រចាំឆ្នាំ៨.៤៥%។

| | | | កំណត់សម្គាល់ ២.១ | |
|---|---|---|---|---|
| | 2020 | 2019 | 2020 | 2019 |
| | $ | $ | ៛'000 | ៛'000 |
| **ប្រាក់កម្ចីធនាគារត្រូវសងវិញគ្រប់ចំនួនក្នុងឆ្នាំ២០២២ ដែលអាចបង់មុនដោយគ្មានការពិន័យ** | | | | |
| ចំណែកបច្ចុប្បន្ននៃប្រាក់កម្ចីធនាគារ | 106.073 | 90.320 | 429.065 | 368.055 |
| ចំណែកមិនមែនបច្ចុប្បន្ននៃប្រាក់កម្ចីធនាគារ | 215.328 | 321.401 | 871.003 | 1.309.710 |
| | **321.401** | **411.721** | **1.300.068** | **1.677.765** |

## ១៣. បំណុលពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់លើភាពខុសគ្នាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធរបស់ពួកគេ។ ពន្ធពន្យារត្រូវបានគណនាដោយប្រើប្រាស់អត្រាពន្ធលើប្រាក់ចំណេញ ២០% ដែលត្រូវបានរំពឹងទុកថាត្រូវអនុវត្តទៅលើប្រាក់ចំណេញជាប់ពន្ធ (ខាតប្រាក់ពន្ធ) នៃការិយបរិច្ឆេទដែលក្នុងការិយបរិច្ឆេទនោះ ទ្រព្យសកម្មពន្ធពន្យារនោះនឹងត្រូវបានក្លាយជាការពិត ឬបំណុលពន្ធពន្យារនោះនឹងត្រូវបានទូទាត់។ ក្រុមហ៊ុនមានសិទ្ធិនិងសមត្ថភាព ក្នុងការទូទាត់ទ្រព្យសកម្មនិងបំណុលពន្ធពន្យារតាមមូលដ្ឋានសុទ្ធ។ ភាពខុសគ្នាបណ្តោះអាសន្នកើតឡើងជាចម្បងដោយសារភាពខុសគ្នា រវាងរំលស់គណនេយ្យនិងរំលស់សម្រាប់គោលបំណងពន្ធ ក៏ដូចជាអត្ថប្រយោជន៍អតីតភាពការងារអនុវត្តត្រឡប់ក្រោយដែលត្រូវបានអនុញ្ញាត សម្រាប់គោលបំណងពន្ធប៉ុណ្ណោះនៅពេលបានទូទាត់។

ក្រុមហ៊ុនមាន បំណុល (ទ្រព្យសកម្ម) ពន្ធពន្យារសុទ្ធមួយ ដែលកើតឡើងពីការពីភាពខុសគ្នាបណ្តោះអាសន្នសម្រាប់ថ្នាក់នៃទ្រព្យសកម្ម និងបំណុលដូចខាងក្រោម ៖

| | អត្ថប្រយោជន៍អតីតភាពការងារ | ដី និង អាគារ | កុំព្យូទ័រ និង បរិក្ខារ | បំណុលពន្ធពន្យារសុទ្ធ |
|---|---|---|---|---|
| | $ | $ | $ | $ |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩** | **(13.000)** | **35.280** | **50.281** | **72.561** |
| ចំណាយ (ឥណទាន) ពន្ធ | (2.108) | 13.760 | 11.481 | 23.133 |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | **(15.108)** | **49.040** | **61.762** | **95.694** |
| ចំណាយ (ឥណទាន) ពន្ធ | 3.162 | 10.760 | 3.598 | 14.358 |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **(11.946)** | **59.800** | **65.360** | **113.215** |

| | កំណត់សម្គាល់ ២.១ | | | |
|---|---|---|---|---|
| | អត្ថប្រយោជន៍អតីតភាពការងារ | ដី និង អាគារ | កុំព្យូទ័រ និង បរិក្ខារ | សរុប |
| | រ៉'000 | រ៉'000 | រ៉'000 | រ៉'000 |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩** | **(52.195)** | **141.649** | **201.879** | **291.333** |
| ចំណាយ (ឥណទាន) ពន្ធ | (8.631) | 56.347 | 47.014 | 94.730 |
| (ផលចំណេញ)/ខាតការបកប្រែរូបិយប័ណ្ណ | (738) | 1.842 | 2.787 | 3.891 |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | **(61.564)** | **199.838** | **251.681** | **389.955** |
| ចំណាយ (ឥណទាន) ពន្ធ | 12.839 | 43.686 | 14.609 | 71.133 |
| (ផលចំណេញ)/ខាតការបកប្រែរូបិយប័ណ្ណ | 406 | (1.633) | (1.907) | (3.134) |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **(48.320)** | **241.891** | **264.383** | **457.954** |

## ១៤. មូលធនភាគហ៊ុន

សមតុល្យនៃមូលធនភាគហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង២០១៩ មានចំនួន $២.០០០.០០០ (រ៨.០៣០.០០០.០០០) រួមមានភាគហ៊ុនធម្មតា ២.០០០.០០០ ជាមួយនឹងតម្លៃលើសន្លឹកហ៊ុន$១ក្នុងហ៊ុននីមួយៗ បានបង់គ្រប់ បានបោះផ្សាយនិងចរាចរណ៍។ ៥០០.០០០ហ៊ុនក្រៅពីនេះត្រូវបានអនុម័តប៉ុន្តែមិនទាន់បានបោះផ្សាយ។

## ១៥. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក្រុមហ៊ុនបានលក់ទំនិញទៅឱ្យ Happy Cake Co. Ltd. ដែលជាក្រុមហ៊ុនមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃម្ចាស់ភាគហ៊ុនភាគច្រើននៃ Cute Candle Co. Ltd.។ គណនីត្រូវទទួលគឺមិនមានការធានា ហើយពុំមានកាលបរិច្ឆេទកំណត់ឱ្យបង់ជាក់លាក់ឡើយ។ ការលក់ និងគណនីត្រូវទទួលទាំងនេះ មានដូចខាងក្រោម ៖

| | | | កំណត់សម្គាល់ ២.១ | |
|---|---|---|---|---|
| | 2020 | 2019 | 2020 | 2019 |
| | $ | $ | រ៉'000 | រ៉'000 |
| ការលក់ទំនិញ | 10.000 | 8.000 | 40.450 | 32.600 |
| គណនីត្រូវទទួល | 3.500 | 2.500 | 14.158 | 10.188 |

លាភការសរុបរបស់អភិបាល និងសមាជិកផ្សេងទៀតនៃបុគ្គលិកគ្រប់គ្រងសំខាន់ៗក្នុងឆ្នាំ២០២០ (រួមមាន ប្រាក់បៀវត្ស និងអត្ថប្រយោជន៍នានា) មានចំនួន $១៧៩.៩៤២ (រ៧៣០.៥៦៤.៥២០) ហើយក្នុងឆ្នាំ២០១៩ មានចំនួន $១៤៥.៧៨២ (រ៥៩៦.៩៧៧.២៩០)។

## ១៦. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវបានអនុម័តឱ្យចេញផ្សាយនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

# Cute Candle Co. Ltd.

## Financial Statements

for the year ended
31 December 2020

All information in these financial statements is fictional and are used for educational purposes only.

# Statement of income and retained earnings

## for the year ended 31 December 2020

| | | | | Supplemental Information Note 2.1 | |
|---|---|---|---|---|---|
| | **Notes** | **2020** | **2019** | **2020** | **2019** |
| | | **$** | **$** | **៛'000** | **៛'000** |
| Revenue | 3 | 7,008,730 | 6,037,830 | 28,350,313 | 24,604,157 |
| Rental income | 4 | 88,850 | 25,000 | 359,398 | 101,875 |
| Fair value gain/(loss) on investment property | 5 | (10,000) | 33,000 | (40,450) | 134,475 |
| Change in inventories of finished goods and work-in-progress | | 20,763 | (12,920) | 83,986 | (52,649) |
| Raw materials and consumables used | | (5,228,832) | (4,028,983) | (21,150,625) | (16,418,106) |
| Employee benefits expense | | (438,000) | (402,000) | (1,771,710) | (1,638,150) |
| Depreciation and amortization expense | | (261,519) | (235,525) | (1,057,843) | (959,764) |
| Rent expense | 6 | (240,000) | (240,000) | (970,800) | (978,000) |
| Utilities expense | | (60,000) | (48,000) | (242,700) | (195,600) |
| Delivery expense | | (55,550) | (56,800) | (224,700) | (231,460) |
| Advertising expense | | (110,000) | (108,000) | (444,950) | (440,100) |
| Other expenses | | (41,211) | (33,029) | (166,698) | (134,593) |
| **Operating profit** | | **673,231** | **930,573** | **2,723,220** | **3,792,085** |
| Bank account interest income | | 5,895 | 3,466 | 23,845 | 14,124 |
| Bank loan interest expense | | (32,558) | (39,483) | (131,696) | (160,895) |
| **Profit before tax** | | **646,569** | **894,556** | **2,615,370** | **3,645,314** |
| Income tax expense | 7 | (129,796) | (179,537) | (525,024) | (731,612) |
| **Profit for the year** | | **516,773** | **715,019** | **2,090,346** | **2,913,702** |
| Retained earnings at the start of the year | | 2,484,981 | 2,169,962 | 10,051,748 | 8,842,595 |
| Dividends | | (300,000) | (400,000) | (1,213,500) | (1,630,000) |
| **Retained earnings at the end of the year** | | **2,701,754** | **2,484,981** | **10,928,594** | **10,126,297** |

# Statement of Financial Position

## for the year ended 31 December 2020

| | Notes | 2020 | 2019 | Supplemental Information Note 2.1 2020 | Supplemental Information Note 2.1 2019 |
|---|---|---|---|---|---|
| | | $ | $ | ៛'000 | ៛'000 |
| **ASSETS** | | | | | |
| **Current assets** | | | | | |
| Cash | | 884,538 | 773,189 | 3,577,956 | 3,150,746 |
| Trade receivables | | 139,508 | 97,515 | 564,311 | 397,375 |
| Inventories | 8 | 118,964 | 90,564 | 481,209 | 369,048 |
| **Total Current assets** | | **1,143,010** | **961,269** | **4,623,476** | **3,917,169** |
| **Non-current assets** | | | | | |
| Intangible assets | | 5,200 | 7,800 | 21,034 | 31,785 |
| Investment property at fair value | 5 | 273,000 | 283,000 | 1,104,285 | 1,153,225 |
| Property and equipment | 9 | 4,031,431 | 4,082,400 | 16,307,139 | 16,635,780 |
| **Total non-current assets** | | **4,309,631** | **4,373,200** | **17,432,458** | **17,820,790** |
| **Total assets** | | **5,452,641** | **5,334,469** | **22,055,934** | **21,737,959** |
| | | | | | |
| **LIABILITIES AND EQUITY** | | | | | |
| **Current liabilities** | | | | | |
| Trade and other payables | 10 | 92,205 | 75,879 | 372,970 | 309,208 |
| Rent payable | 6 | 20,000 | 20,000 | 80,900 | 81,500 |
| Current tax payable | 7 | 103,390 | 153,904 | 418,214 | 627,157 |
| Employee benefits payable | 11 | 54,228 | 34,840 | 219,352 | 141,973 |
| Current portion of bank loan | 12 | 106,073 | 90,320 | 429,065 | 368,055 |
| **Total current liabilities** | | **375,896** | **374,943** | **1,520,501** | **1,527,894** |
| **Non-current liabilities** | | | | | |
| Employee benefits payable | 11 | 43,286 | 57,449 | 175,092 | 234,105 |
| Deferred tax liability | 13 | 113,215 | 95,694 | 457,954 | 389,955 |
| Bank loan | 12 | 215,328 | 321,401 | 871,003 | 1,309,710 |
| **Total non-current liabilities** | | **371,829** | **474,545** | **1,504,048** | **1,933,769** |
| **Total liabilities** | | **750,888** | **849,488** | **3,037,340** | **3,461,662** |
| **Equity** | | | | | |
| Share capital | 14 | 2,000,000 | 2,000,000 | 8,090,000 | 8,150,000 |
| Retained earnings | | 2,701,754 | 2,484,981 | 10,928,594 | 10,126,297 |
| **Total equity** | | **4,701,754** | **4,484,981** | **19,018,594** | **18,276,297** |
| **Total liabilities and equity** | | **5,452,641** | **5,334,469** | **22,055,934** | **21,737,959** |

# Statement of Cash Flows

## for the year ended 31 December 2020

| | Notes | 2020 | 2019 | Supplemental Information Note 2.1 2020 | 2019 |
|---|---|---|---|---|---|
| | | $ | $ | ៛'000 | ៛'000 |
| **Cash flows from operating activities** | | | | | |
| Operating profit for the year | | 673,231 | 930,573 | 2,723,220 | 3,792,085 |
| *Adjustments for non-operating and non-cash items:* | | | | | |
| Fair value gain or loss on investment property | | 10,000 | (33,000) | 40,450 | (134,475) |
| Depreciation of property, plant and equipment | | 261,519 | 235,525 | 1,057,843 | 959,764 |
| *Changes in operating assets and liabilities:* | | | | | |
| Increase in trade and other receivables | | (41,993) | (11,068) | (169,861) | (45,101) |
| Increase in inventories | | (28,400) | (13,585) | (114,878) | (55,357) |
| Increase in trade and lease payables | | 16,326 | 11,151 | 66,038 | 45,440 |
| Increase in employee benefits payable | | 5,225 | 13,051 | 21,135 | 53,183 |
| **Cash generated from operating activities** | | **895,908** | **1,132,648** | **3,623,948** | **4,615,539** |
| Bank account interest received | | **5,895** | **3,466** | 23,845 | 14,124 |
| Bank loan interest paid | | (32,558) | (39,483) | (131,696) | (160,895) |
| Income tax paid | | (162,789) | (87,500) | (658,480) | (356,563) |
| **Net cash inflow from operating activities** | | **706,457** | **1,009,130** | **2,857,618** | **4,112,205** |
| **Cash flows from investing activities** | | | | | |
| Purchases of equipment | 9 | (207,950) | (242,300) | (841,158) | (987,373) |
| **Net cash used in investing activities** | | **(207,950)** | **(242,300)** | **(841,158)** | **(987,373)** |
| **Cash flows from financing activities** | | | | | |
| Payment of bank loan | | (90,320) | (83,029) | (365,346) | (338,341) |
| Dividends paid | | (300,000) | (400,000) | (1,213,500) | (1,630,000) |
| **Net cash used in financing activities** | | **(390,320)** | **(483,029)** | **(1,578,846)** | **(1,968,341)** |
| **Net increase (decrease) in cash** | | **111,349** | **283,802** | 450,405 | 1,156,491 |
| Cash | | **773,189** | **489,388** | 3,127,550 | 1,994,255 |
| **Cash at end of year** | | **884,538** | **773,189** | **3,577,956** | **3,150,746** |

# Notes to the financial statements

## for the year ended 31 December 2020

## 1. General information

Cute Candle Company Limited (the "Company") has its registered office and principal place of business at 64 Street 108, Sangkat Wat Phnom, Phnom Penh, Cambodia. The principal activities are the manufacture and sale of candles.

## 2. Basis of preparation and significant accounting policies

These financial statements have been prepared in accordance with the Cambodian International Financial Reporting Standard for Small and Medium-sized Entities ("CIFRS for SMEs") issued by the Accounting and Auditing Regulator of Cambodia and the International Financial Reporting Standard for Small and Medium Sized Entities ("IFRS for SMEs") issued by the International Accounting Standards Board. Accounting policies follow the requirements of CIFRS for SMEs and IFRS for SMEs. Material Company specific accounting policies and policy choices are presented in the notes below.

The date of transition to CIFRS for SMEs and IFRS for SMEs is 1 January 2019. These are the first general purpose financial statements prepared by the company; therefore, there are no changes in policies or measurements from any previous general purpose financial statements."

### 2.1 Currency

These financial statements are presented in US dollars, the functional currency of the Company. Revenue and expenses of the Company are mainly denominated and settled in US dollars. The translation of the US dollar amounts into Cambodian riel is supplemental information presented in the financial statements to comply with the Cambodian Law on Accounting and Auditing. To make the translation useful for tax reporting purposes, the translation uses the closing exchange rate of ៛4,045:$1 (2019: ៛4,075:$1; 2018: ៛4,018:$1), as announced by the National Bank of Cambodia.

## 3. Revenue

Revenue from sales of goods is recognised when the goods are delivered by the Company and ownership of the goods has passed when the customer signs acceptance on the delivery note. Revenue is measured at the fair value of the consideration received or receivable, net of discounts and value added tax collected on behalf of the government of Cambodia.

| | | | Supplemental Information Note 2.1 | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| | **$** | **$** | **៛'000** | **៛'000** |
| Sale of goods | 7,008,730 | 6,037,830 | 28,350,313 | 24,604,157 |

## 4. Rental income

Rental income in 2020 of $88,850 (៛364,285,000) and 2019 of $25,000 (៛101,125,000) was earned from an operating lease of a warehouse owned by the Company and recognized as investment property. In 2020 the property was leased to a new tenant for a period ending in July 2022; there is no security deposit held. Non-cancellable lease payments fall due as follows:

| Rental Payments to be Received | | | Supplemental Information Note 2.1 | |
|---|---|---|---|---|
| | 2020 | 2019 | 2020 | 2019 |
| | $ | $ | ៛'000 | ៛'000 |
| Within one year | 88,850 | 25,000 | 359,398 | 101,875 |
| Later than one year but within five years | 44,400 | - | 179,598 | - |
| Later than five years | - | - | - | - |
| **Total future rent receivable** | **133,250** | **25,000** | **538,996** | **101,875** |

## 5. Investment property

Investment property is initially recognised at cost and remeasured to fair value at each year end. Investment property is not depreciated. The investment property of the Company comprises a warehouse and the land on which it sits. The investment property is used to generate rental income as described in note 4 above.

The property was valued by an independent valuer holding a license from the Ministry of Economy and Finance. The valuation method is the comparison method, using the recent sales prices of comparable properties. This accuracy of this valuation method is limited by the infrequent sale of similar properties in the area.

| | | Supplemental Information Note 2.1 |
|---|---|---|
| | Land and Building | Land and Building |
| | $ | ៛'000 |
| 1 January 2020 | 283,000 | 1,144,735 |
| Additions | - | - |
| Fair Value Gain / (Loss) | (10,000) | (40,450) |
| **31 December 2020** | **273,000** | **1,104,285** |

## 6. Rent expense, rent payable

Rent expense is the cost of renting a combined retail space and sales office. The rental agreement is for four years, with 18 months remaining. Fixed rental payments are made on a monthly basis. The rent agreement is classified as an operating lease because the terms of the rent agreement do not transfer substantially all the risks and rewards of ownership of the leased asset to the Company. At year-end, the Company has outstanding non-cancellable payments committed under the rental agreement as follows:

| | | | Supplemental Information Note 2.1 | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| | **$** | **$** | **៛'000** | **៛'000** |
| Within one year | 240,000 | 240,000 | 970,800 | 978,000 |
| Later than one year but within five years | 120,000 | 360,000 | 485,400 | 1,467,000 |
| Later than five years | - | - | - | - |
| **Total future lease payments** | **360,000** | **600,000** | **1,456,200** | **2,445,000** |

## 7. Income tax expense and current tax

Income tax expense comprises current tax and deferred tax (see note 13 on deferred tax). Income tax expense is recognized in profit or loss. Current tax is the tax paid and payable in respect of the taxable income for the year, using tax rates enacted or substantially enacted at year end, and any adjustment to the current tax of previous years. Tax is payable in Cambodian riel; foreign exchange gains and losses are included in finance income and finance costs.

| **Rental Payments to be Received** | | | Supplemental Information Note 2.1 | |
|---|---|---|---|---|
| | **2020** | **2019** | **2020** | **2019** |
| | **$** | **$** | **៛'000** | **៛'000** |
| Current tax payable | 103,390 | 153,904 | 418,214 | 627,157 |
| Withholding tax credit on rental and interest income | 8,885 | 2,500 | 35,940 | 10,188 |
| **Current tax** | **112,275** | **156,404** | **454,154** | **637,345** |
| Change in deferred tax liability (note 13) | 17,520 | 23,133 | 70,870 | 94,268 |
| **Income tax expense** | **129,796** | **179,537** | **525,024** | **731,612** |

Income tax is calculated at 20 percent of the yearly taxable income. Tax expense differs from profit before tax times the tax rate due to non-allowable expenses including bad debt expense and entertainment.

## 8. Inventories

Inventories are stated at the lower of cost and selling price less costs to complete and sell. Cost is calculated using the first-in, first-out (FIFO) method.

At each year end, inventories are assessed for impairment by comparing the carrying amount of each item of inventory (or group of similar items) with its selling price less costs to complete and sell. If an item of inventory (or group of similar items) is impaired, its carrying amount is reduced to selling price less costs to complete and sell, and an impairment loss is recognised immediately in profit or loss. In 2020 there was impairment of inventories in the amount of $11,000 (៛45,100,000) and in 2019 in the amount of $8,306 (៛33,846,950); impairment of inventories is charged to other expenses.

| | 2020 | 2019 | Supplemental Information Note 2.1 2020 | 2019 |
|---|---|---|---|---|
| | **$** | **$** | **៛'000** | **៛'000** |
| Raw materials | 38,300 | 31,900 | 154,924 | 129,993 |
| Work in progress | 28,223 | 22,000 | 114,162 | 89,650 |
| Finished goods | 45,540 | 31,000 | 184,209 | 126,325 |
| Consumable inventories | **6,901** | **5,664** | **27,915** | **23,081** |
| | **118,964** | **90,564** | **481,209** | **369,048** |

## 9. Property and equipment

Property and equipment are measured at cost less accumulated depreciation and accumulated impairment losses. Depreciation expense allocates the cost of assets less their residual values over their estimated useful lives, using the straight-line method. If there is a change in the useful lives or residual values, depreciation is revised prospectively.

Land and building consists of a factory building and the land on which it sits. Equipment consists of candle making equipment, furniture and office equipment. The estimated useful lives are as follows:

Building 50 years

Equipment 5- 8 years

Land is not depreciated. The land element of land and building is presented at its historical cost of $1,250,000. The land and building with a carrying amount of $3,014,000 (៛12,191,630,000) has been pledged as security for a loan with a remaining term of three years (see note 12). During the period of the loan, the land and building may not be sold or transferred.

| | Land and Building | Equipment | Total |
|---|---|---|---|
| **Cost** | **$** | **$** | **$** |
| 1 January 2020 | 3,210,000 | 1,549,800 | 4,759,800 |
| Additions | - | 207,950 | 207,950 |
| Disposals | - | - | - |
| **31 December 2020** | **3,210,000** | **1,757,750** | **4,967,750** |
| **Accumulated depreciation and impairment** | | | |
| 1 January 2020 | 156,800 | 520,600 | 677,400 |
| Depreciation expense | 39,200 | 219,719 | 258,919 |
